**គណបក្សប្រជាជនកម្ពុជា**
**គណៈកម្មាធិការកណ្ដាល**

**ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ**
**អព្យាក្រិត និង វឌ្ឍនភាពសង្គម**

# សេចក្ដីថ្លែងការណ៍របស់ការិយាល័យ
# អ្នកនាំពាក្យ គណបក្សប្រជាជនកម្ពុជា

*********

នៅថ្ងៃទី ១៤ មករា ១៩៩៩ កាសែតប្រចាំថ្ងៃឈ្មោះ « ឌឹ ខេមបូឌា ដេលី » បានចេញផ្សាយនូវអត្ថបទមួយ មួលបង្កាច់យ៉ាងធ្ងន់ធ្ងរមកលើគណបក្សប្រជាជន ដោយបានចោទថា គណបក្សប្រជាជនជាអ្នកបានទទួលផលចំណេញពីការនាំចូលកាកសំណល់ពីតៃវ៉ាន់មកទីក្រុងកំពង់សោម ។

នៅក្នុងទំព័រទីមួយនៃព្រឹត្តប័ត្រជាភាសាអង់គ្លេស និងនៅទំព័រទីមួយនៃព្រឹត្តប័ត្រជាភាសាខ្មែររបស់ខ្លួន កាសែតនេះបានចុះផ្សាយនូវអត្ថបទមួយដែលសរសេរដោយឈ្មោះ Jeff Smith និង វណ្ណ រ៉ឺន ដែលក្នុងនោះអ្នកទាំងពីរនេះបានខិតខំចោទប្រកាន់ដោយគ្មានមូលដ្ឋានថា ប្រាក់មួយភាគដែលបានពីការឃុបឃិតលើលំនាំចូលនៃកាកសំណល់នេះ ត្រូវបានគណបក្សប្រជាជនទទួលយកទៅប្រើសំរាប់យុទ្ធនាការឃោសនារបស់ខ្លួន ។

គណបក្សប្រជាជន សូមទាត់ចោលនូវការចោទប្រកាន់ដ៏ថោកទាបនេះ ហើយសូមប្រកាសជាឧឡារិកថា គណបក្សប្រជាជនគ្មានការទាក់ទងអ្វីជាមួយរឿងដ៏ថោកទាបទាំងនេះទេ ហើយក៏មិនដែលបានទទួលផលចំណេញពីរឿងទាំងនេះឡើយ។ ក្នុងឋានៈជាគណបក្សមួយដែលមានមនសិការទទួលខុសត្រូវចំពោះវាសនារបស់ប្រទេសជាតិ គណបក្សយើងមិនបានលក់ឧត្តមគតិខ្លួន លក់ភាពថ្លៃថ្នូររបស់ខ្លួនដើម្បីប្រាក់នោះឡើយ ហើយយើងក៏មានថវិកាគ្រប់គ្រាន់ដើម្បីធ្វើការឃោសនាដោយថ្លៃថ្នូរ ដោយស្របច្បាប់ និងដោយមិនចាំបាច់ត្រូវការប្រើមធ្យោបាយក្រខ្វក់ណាមួយដើម្បីឈ្នះឆ្នោតនោះក៏ទេដែរ ។ គណបក្សយើងសូមអរគុណយ៉ាងស្មោះអស់ពីដួងចិត្តនូវការរួមចំណែកជាសំភារៈ និងស្មារតីរបស់សមាជិករាប់លាននាក់របស់យើង នៅក្នុងយុទ្ធនាការបោះឆ្នោតកន្លងទៅនេះ ដែលជាកត្តាមួយដ៏សំខាន់រួមចំណែកដល់ជ័យជំនះរបស់គណបក្ស ។ ទន្ទឹមនេះយើងសូមអោយរដ្ឋាភិបាលជំរុញ វែកមុខអោយបានលឿន នូវជនណាដែលបានរួមចំណែកនៅក្នុងរឿងកាកសំណល់ទាំងនេះ ។

ជាថ្មីម្តងទៀត គណបក្សប្រជាជនសូមថ្កោលទោសយ៉ាងម៉ឺងម៉ាត់នូវសកម្មភាពប្រើសិទ្ធិសេរីភាពសារព័ត៌មានដើម្បីមួលបង្កាច់វាយប្រហារ បង្អាប់បន្ថោកកិត្តិយសអ្នកដទៃ ដូចដែលឈ្មោះ Jeff Smith និង វណ្ណ រ៉ឺន បានធ្វើនេះ ហើយដែលជាការអួរប៉ះពាល់យ៉ាងខ្លាំងដល់អ្នកកាសែតឯទៀត ដែលបានបំពេញការងាររបស់ខ្លួនយ៉ាងត្រឹមត្រូវ ស្របតាមក្រមសីលធម៌របស់ខ្លួន ។

*ភ្នំពេញ ថ្ងៃទី ១៤ មករា ១៩៩៩*